**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គនាយកដ្ឋានកសិកម្ម**

លេខ...១៣៦២...អ.ន.ក

ថ្ងៃ...ច័ន្ទ ២ កើត...ខែ...អាសាឍ...ឆ្នាំ...ច សំរឹទ្ធិស័ក...ព.ស.២៥៦២.
រាជធានីភ្នំពេញ ថ្ងៃទី...១៦...ខែ...កក្កដា...ឆ្នាំ២០១៨.

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ៖** របាយការណ៍ស្តីពីសកម្មភាពអនុវត្តការងារប្រចាំឆមាសទី១ ឆ្នាំ២០១៨ របស់អគ្គនាយកដ្ឋានកសិកម្ម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតរាយការណ៍ជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាប នូវលទ្ធផលអនុវត្តសកម្មភាពការងាររបស់អគ្គនាយកដ្ឋានកសិកម្មប្រចាំឆមាសទី១ ឆ្នាំ២០១៨ មានដូចខាងក្រោម៖

I. **លទ្ធផលបង្កបង្កើនផលកសិកម្មរដូវវស្សាឆ្នាំ២០១៨** (គិតត្រឹមថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨)

**១. ដំណាំស្រូវ** : ផ្ទៃដីស្ទូងព្រោះសរុបអនុវត្តបានចំនួន ១.៤៩៨.២០២ ហ.ត ស្មើនឹង ៥៩,៦០% នៃផែនការចំនួន ២.៥១៣.៨៩៥ ហ.ត លឿនជាងឆ្នាំមុនចំនួន ២៣៩.៧១៤ ហ.ត

- ការងារភ្ជួររាស់ដី : ផ្ទៃដីភ្ជួររាស់សរុបអនុវត្តបានចំនួន ១.៧៩២.៧៨៨ ហ.ត លឿនជាងឆ្នាំមុនចំនួន ៩៥.២១៣ ហ.ត ក្នុងនោះផ្ទៃដីភ្ជួររាស់ដោយគ្រឿងយន្តចំនួន ១.៧៣៥.៩៤០ ហ.ត ស្មើនឹង៩៦,៨២%
- ផ្ទៃដីសាបសរុប : ១៩.៥៦៩ ហ.ត លឿនជាងឆ្នាំមុនចំនួន ២.៥៧៥ ហ.ត។




*ក្រាហ្វិក៖ ស្ថិតិផ្ទៃដីភ្ជួររាស់ និងដាំដុះស្រូវរដូវវស្សាពីឆ្នាំ២០១៤-២០១៨ គិតត្រឹមឆមាសទី១នៃឆ្នាំ*

តាមក្រាហ្វិកខាងលើបង្ហាញថា គិតត្រឹមឆមាសទី១ ឆ្នាំ២០១៨ ផ្ទៃដីភ្ជួររាស់ និងផ្ទៃដីដាំដុះស្រូវរដូវវស្សាឆ្នាំ ២០១៨ មានការកើនឡើងជាងបណ្តាឆ្នាំមុនៗ បើប្រៀបធៀបរយៈពេលដូចគ្នា៥ឆ្នាំចុងក្រោយ។

**២. ដំណាំរួមផ្សំ** : អនុវត្តបានចំនួន ២៦.១៦២ ហ.ត លឿនជាងឆ្នាំមុនចំនួន ១.៣២៣ ហ.ត។

**៣. ដំណាំឧស្សាហកម្ម** : អនុវត្តបានចំនួន ៧២៥.២៩៥ ហ.ត យឺតជាងឆ្នាំមុនចំនួន ៥០.៨៧៥ ហ.ត។



អាសយដ្ឋានលេខ: ៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទលេខ:(០២៣) ៨៨៣ ៤២៧ ទូរសារលេខ:(០២៣) ៨៨៣ ៤២៧
Address # 54B/49F, Street 395-656, Sangkat Toeuk Laak 3, Khan Tuol Kok, Phnom Penh. Cambodia, Phone : (023) 883 427, Fax : (023) 883 427